# ច្បាប់ល្បើកថ្មី

អ្នកព្រះភិរម្យ ភាសាអ៊ីខ្ញុំ បង្គំឱកគុណ
ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃជាមុខ គុណតាប់មហាធ្ងន់
មាតាបិតា ។

ឧបជ្ឈាយ៍ជាធំ កាលចាប់ដៃខ្ញុំ ឱ្យធម៌ទេសនា
មនុសភាវធ ព្រះកម្មវាចា គុណធម៌អក្ខរា
ទាំងសាមសិបបី ។

ខែចេត្រឆ្នាំច ចត្វាស័កក កត់ពាក្យថ្មី
បើកច្បាប់ប្រដៅ កូនចៅប្រុសស្រី តូចក្តីធំក្តី
ចូរស្តាប់គ្រប់គ្នា ។

ក្បិតមនុស្សឥឡូវ យកខុសជាត្រូវ យកភូតធ្វើជា
អំពើអាក្រក់ ឱ្យឡូកលើពក ព្រលើងពានពារ
អាងមាសអាងប្រាក់ ។

អាងព្រើលអាងប្រាជ្ញ អាងកោងអាងកាច អាងកាប់អាងចាក់
អាងជើងអាងដៃ អាងវាយអាងចាក់ អាងគុកច្រវាក់
អាងអំណាចកាត់ក ។



អាងសុខតែខុស កូនឆើយចាំពុះ អាងនោះមិនល្អ
អ្នកគិតឱ្យល្អិត ល្បិតស្រុកលោកប្រ ប្រមាណដំណា
តទៀតទៅមុខ ។

សាសនាទៅឆ្ងាយ លែងបានសប្បាយ មានតែកើតទុក្ខ
កើតទាស់លោកិយ ឆ្លៃចំពុក ជំណែលមាតុក
ចូរចាំគ្រប់គ្នា ។

អ្នកជឿពាក្យចាស់ ជឿចាំឱ្យណាស់ កុំធ្វើបំពា
អ្នកហិនស្បែកផាង អ្នកខ្វាងស្បែកផា មនុស្សពើពៀ
កុំយកខ្លួនល្បៀត ។

ឃើញអ្នកគេល្អ ទោះបីមានប្រ យកគេជាញាតិ
គួរគាប់អ្នកក្រៅ ចៅអ្នកឯទៀត រាប់រើសមាយោគ
សុចរិតត្រឹមត្រូវ ។

រៀនបទរៀនចាទ កុំកោងហួសខ្នាត កុំភ្ញាត់ហួសផ្លូវ
កុំភ្លើនហួសរ៉ៃ កុំប្រែហួសទី ឃើញចាស់សក់ស្កូវ
កុំស្ងរមើលងាយ ។

បន្ទន់អាត្មា ខ្លាចមេខ្លាចពា ខ្លាចតាខ្លាចយាយ
បំរើមហាក្សត្រ ប្រយ័ត្នស្មេចទាយ ពាក្យពិតចំនាយ
រលាយកេរ្តិ៍ឈ្មោះ ។

ពាក្យស្តេចពាក្យគ្រូ  មានប្រមាណផ្ទួន  កម្រពីរោះ
ផ្ចិតចាយឱ្យចាប  ផ្ចិតចាយឱ្យខ្ពស់  ចាយឱ្យស័ក្តិយស
ចាយចុះកុំរឹង ។

បម្រើមើលភេទ  ចំណាំព្រះនេត្រ  ហេតុខ្លួនឱ្យដឹង
ខ្លួនខ្ពស់បែរព្រើល  លោកមើលសំឡឹង  ស៊ុឡុកឱ្យប្រឹង
ចំប្រិតរៀនសូត្រ ។

បម្រើមើលពុត  ត្រងថ្ងាឱ្យមុត  ស្មារតីឱ្យមាន
បើខ្វះឱ្យព្រួញ  បើខ្វាចឱ្យហ៊ាន  ចង់ចាំរបៀន
កុំអៀនកុំខ្មាស ។

ពុតលោកជាធំ  ត្រូវនោបុំឆ្នាំ  ឯងមើលមិនច្បាស់
បម្រើលោកណា  លោកប្រឹងជាម្ចាស់  លោកស្អប់អ្វីណាស់
ត្រាសចោលឱ្យឆ្ងាយ ។

កុំឈមឈរជិត  កុំយកធ្វើមិត្ត .  ភ្ជាប់ខ្លួនអន្តរាយ
បើប្រពន្ធកូន  បងប្អូនចៅហ្វាយ  មាតុកឬម្តាយ
និងកាយប្រតិបត្តិ ។

អ្នកកុំមើលងាយ .  ឃើញគេរីករាយ  ព្រួញខ្លួនប្រយ័ត្ន
ត្រកូលញាតិផៅ  កូនចៅមហាក្សត្រ  ស្មើធ្វើមប្រមាត់
ប្រមាថមិនបាន ។



នោះអ្នកផងទៃ  អ្នកគ្រៀងអ្នកក្រៃ  ដែលគេលោករាប់អាន
កុំថាតែមនុស្ស  នោះគេតិរច្ឆាន  ឯងស្អប់បំផ្លាន
កុំហ៊ានប្រមាថ ។

របស់ឬទ្រព្យ  ដែលចាស់សំអប់  កុំពាច់សំអាត
ទ្រព្យណាស់ឡាញ់  អស់អញ្ជវិបាក  ក្បូរចោលស្អាត
ជួយថែរក្សា ។

កុំជិះកុំជាន់  ស្មើថ្មីអាចម៍មាន់  ពាក្យចាស់ឧបមា
បុរាណពោលថ្វី  ពីរបីប្រការ  កុំស៊ីគ្រប់ណា
ចុះផាក់គ្រប់រឿង ។

សាច់សការលោកពិត  កុំដូរស្រែកពិត  ខ្លួនទោសកើតឡើង
មាតុកថ្លៃថ្លាំ  ក្បូរចាំតេះថ្លឹង  សាច់ធ្វើមស្លូតឡឹង
និងស្បែកខាងក្រៅ ។

សាច់ស្លូតក្នុងខ្លួន  ទុកស្មើបងប្អូន  ប្រពន្ធកូនចៅ
សរសៃនិងស្បែក  ចែកញាតិជាផៅ  ខ្ញុំស្រីខាងក្រៅ
ជាស្មៅអាចម៍មាន់ ។

ស្រីខ្ញុំកំដរ  បើឃើញរូបល្អ  កុំលលួកលាង
កុំលួចលេបលេង  ក្រែងម្ចាស់គេខាន់  កុំកប់កុំភាន់
អាប់អប់អាត្មា ។

បើអ្នកមានយស មានសក្តិខ្ពង់ខ្ពស់ គាប់ចិត្តរាជការ
ធ្វើធំធ្វើចៅ មន្ត្រីមានត្រា ព្រះហ្លួង ឧកញ៉ា
សាលាកុង្ស៊ីយ៍ ។

ទោះច្បាប់បារាំង កុំភ្លេចសត្វំ កត្តញ្ញូខ្មី
កុំធ្វើបហូសមាន ភ្លេចញាតិ ប្រុស ស្រី ជុំគ្នាកាត់ក្ដី
យក ឧបេក្ខា ។

កុំកាន់សីហលោ កុំកាន់លោភោ ទោសោមោហោ
កុំជក់អាភៀន កុំឃ្លានផឹកស្រា កុំល្បប់ខាងណា
សក្ខាយកគ្រង់ ។

ល្បួងលោមពិសោធន៍ កុំឆបញ្ឆោត បញ្ចុះឱ្យបង់
ឱ្យបែកឱ្យបាក់ ពាក្យសត្យពាក្យសច្ច កុំមើលឱ្យធ្វើផ្ទង់
តម្រង់ល្បារគី ។

កុំភ្លើតភ្លេចប្រាក់ កុំភ្លើភ្ញាត់សក្តិ ធ្លាក់ទោរវិធី
កាន់ធម៌ទសពិធ រិតឡើងរាសី គាប់ពីលោកិយ
ដល់បរលោកខាយ ។

អ្នកក្ដីជាភ្ញើង កុំកាត់កាន់ជើង អ្នកម្ខាងមើលងាយ
ទៅក្រមជាចិត រ៉ូតករំលោយ កុំជេរកុំវាយ
បង្ខំនាំខុស ។



ទោរខុចល្អចប្ចង់ វិទោរស្ម័គ្រស្លន់ កញ្ញា ប្រុស ស្រី
កុំល្បប់ខាងណោះ បញ្ចុះខាងណោះ ល្អងលោមបញ្ចុះ
បញ្ចូលចិត្តក្ដី ។

កុំផុតឱ្យក្ដៅ បើឃើញគ្នាខ្លៅ ប្រាជ្ញាគ្នាខ្ចី
កុំឃ្លាន ប្រាក់ ប្រុស បន្ទុះខាង ស្រី បើកាន់ច្បាប់ថ្មី
កុំចោលច្បាប់ចាស់ ។

កុំជឿលអ្នកស្រែ ព្រកួលឯងខ្មែរ កុំប្រែ ក្រឡាស់
ព្រឡោកឃើញគុណ ខន់ខ្វួចសំពះ កុំធ្វើអួតណាស់
កុំគ្នះអ្នក ក្រ ។

អ្នកកុំភ្លេចគុណ គ្រូលោចពុទ្ធ គ្រូស្រ គ្រូអក្សរ
កុំចាប់ដៃទាញ ពីទាប់ងក់ កុំផ្ដែកត
ស្មើមិត្តសំឡាញ់ ។

រាស្ត្រពេញចូល ស្រុក សួរសោភទៅមក កុំអើចឯងអញ
ពាក្យពុំពីរោះ គេកើតមួម៉ាញ់ គេជៀលថ្នាលថ្នាញ់
អន្តរាយកើ្ត ។

កុំធ្វើងអាងបុណ្យ ស្រដីឱ្យខន់ ពោលពាក្យពីរោះ
ខ្លួនអ្នកនឹងថ្កើង នឹងឡើងសក្តិយស កុំឡៀតទាំឈ្មោះ
ញុះញង់អ្នកធំ ។

កុំស្អប់អ្នកតូច    បើឃើញគ្នាខុច    គួរគិតប្រមុំ
ទោសគ្នាតិចតួច    ផ្ទួចឡើងជាធំ    ផ្សែងពុកជាផ្ចុំ
ផ្ទុំឆេះជាភ្លើង ។

កុំភ្លើនភ្លេចខ្លួន    ចេះសាសន៍បិនយូន    កុំចោលខ្មែរយើង
កុំធ្វើក្រអឺត    កុំពើតកុំពើង    កុំពាក់ស្បែកជើង
ចូលវត្តលោកសង្ឃ ។

ដោះមួកដាក់ម័ត្រ    និងកាយប្រតិបត្តិ    លំអុកនិងអង្គ
កុំស៊ីតាមឃ្លាន    កុំហ៊ានតាមចង់    កាន់ច្បាប់ស្រុកប្រុង[illegible]
កុំបង់សាសនា ។

កុំចង់ជើងពេក    កុំលើកដំណេក    ហួសមេហួសពា
តែងខ្លួនឱ្យល្មម    មើលពូជពង្សា    សម្ដេចបិត្តិតា
រឿងធ្លាប់បុណ្យសក្តិ ។



បើទោះជារាស្ត្រ    ក្រផ្ទាវែលញ្ញាស    គួរវាសឈូកឈ្លាក់
ឱ្យឃ្លៀតវែកពុន    បើចូចសុំដាក់    ទំរកមាសប្រាក់
ឱ្យគ្រាន់ទាច់ចាយ ។

រាជការវាំងសេស    កុចក៏ប្រើបរស    កុំឆ្អមរូបកាយ
ដើរគិតដេកគិត    ផ្ញុញជិតផ្ញុញឆ្ងាយ    បើចង់សប្បាយ
ស្រេចនៅមានទ្រព្យ ។

រាស្ត្រហ្លួងពីមុន    រកស៊ីវែកពុន    មានក្រតាមភ័ព្វ
រាស្ត្រលោកឥឡូវ    ត្រូវទំឱ្យធ្លាប់    តែខ្ជិលច្រើនជាប់
ខ្លោះជើងខ្លោះដៃ ។

តាំងពីឆ្នាំច    ចាំជាដំណក    ខំមិញឡើងថ្លៃ
ចងក្បិនឱ្យតឹង    ប្រឹងកុំសឹចៃ    សព្វរៀងយប់ថ្ងៃ
កុំឱ្យក្រខ្សត់ ។

បើចង់ស្រោលខ្លួន    រៀនស្មគ្រឱ្យមុន    ឱ្យមាំឱ្យស្ទាត់
កុំចេះស្ទាក់ស្ទើ    ល្ងីល្ងើឥតបទ    បើចេះក្រាកដ
ប្រាក់រត់តាមហៅ ។

កុំថ្នមកម្លាំង    កាប់ដីកូកចាំង    កុំខ្លាចរងាក្តៅ
រៀនអ្វីឱ្យឈ្លិន    កុំឱ្យខ្លាចនៅ    កុំដេកតែខ្ទៅ
ក្រក្រៅសណ្ដាប់ ។

បើល្ងង់ឲ្យចេះ    រករៀនត្រិះ    រិះរកត្រាប់
ឥត្រើយល្បងស្គាំ    កុំចាំគេប្រាប់    រៀនល្អីរៀនស្តាប់
រៀនមើលឲ្យស្ទែង ។

កើតមកជាមនុស្ស    ទាំងស្រីទាំងប្រុស    មិនដែលចេះឯង
បើក្រឲ្យមាន    វិញ្ញាណចេះក្រែង    គិតគ្រប់កន្លែង
កុំដេកតែក្រ ។

កុំប្លន់កុំលួច    កុំខ្ជិលកុំខូច    កុហកឆ្ងវ
ចោកប្រាសយកប្រាក់    ត្រវាក់ជាប់ក    កាន់មាយាទល្អ
សុចរិតត្រឹមត្រូវ ។

កូនអើយរកស៊ី    កកាយធរណី    ធ្វើស្រែយកស្រូវ
កុំតាមអ្នកណា    ពុតាមតែទី    បើកភ្នែកមិលផ្លូវ
កុំស្រាស់បន្ទា ។

គេដើរយប់ថ្ងៃ    មុតជើងមុតដៃ    ហឹងល្អៀសទៅណា
ល្អៀសចុះដាច់ស្រូវ    ហើយដេរផ្កាសា    កូនម្តាយអាណា
ស្រាវស់ជើរមិនរួច ។

កុំយកគល់ឈើ    ទៅដាក់ពីលើ    ទោះធំទោះតូច
ជំពប់ជើងគេ    គេថាឯងខូច    ដេរជៀលផល់ពួច
ប្រផុចមេធា ។



បើកភ្នែកឲ្យធំ    បណ្ដាប់ឲ្យមាំ    គាប់ភ្នែកទេវតា
ស្មើពានសល់ស្អាត    និងមានបញ្ញា    កើតសាធុការ
អាយុយឺនវែង ។

កូនអើយធរណី    បើតាមគម្ពីរ    ដែលលោកសម្តែង
កុំចង់បានធំ    ប្រមុំឲ្យលង្វែង    កុំលើកដីឯង
លបដាក់ស្រែគេ ។

អំពើអាក្រក់    មួយចំរៀកសក់    ធ្លាក់ទៅនិរយ
បច្ចុប្បន្នលោកិយ    កើតក្តីវាយដេរ    មិនដែលសុខទេ
ព្រោះតែមួយហេតុ ។

កុំផ្ញួចចង់ទាស់    ខូចខាតរបស់    អស់ទ្រព្យសម្បត្តិ
ចង់គង់ប្រយោជន៍    ឲ្យចេះប្រព្រឹត្ត    ពាក្យនីមួយម៉ាត់
ឲ្យគិតមួយម៉ោង ។

សំអាតផ្ទិតផ្ទង់    លើកភ្នែកឲ្យត្រង់    កុំលើកឲ្យកោង
អ្នកកុំប្រហែស    ក្រែងមានប្រហោង    លើកមើលទំនង
ទំនាបទឹកហូរ ។

ចំនួនទឹកស្អឹង    ទឹកព្រែកទឹកបឹង    ទឹកវាលទឹកអូរ
អ្នកលើលិចស្រូវ    ត្រូវបើកបង្ហូរ    អ្នកក្រោមកុំថ្ងូរ
បង្ហូរហូសទៅ ។

រាំងរែងយប់ថ្ងៃ　ទ្វារបើកទ្វារបិទ　កុំឱ្យចាក់ផ្ដៅ
កន្តិកចេញខ្យល់　ពម្នល់ទឹកនៅ　បើចង់បានស្រូវ
បានទៅត្រឹមថៃ ។

កុំយកគ្រាប់ត្នោត　ទៅដាំទៅដោត　នៅលើភ្លឺស្រែ
ចិត្តគិតប្រមាណ　ចង់បានផ្កាផ្លែ　ដាំដុះបន្លែ
បន្លិនខ្លួនឯង ។

ដល់ត្នោតឡើងគល់　ឡើងកើតទាំខ្វល់　ធាងលូតឡើងវែង
ភ្ជួររាស់ផ្កាប់ផឹម　ក្របីផ្កាប់ស្នែង　ខ្ជើសខ្ជែង
ភ្ជួររឿងមិនត្រូវ ។

ដល់ត្នោតវាធំ　មានស្លឹកវាទុំ　វាគ្រុះក្នុងស្រូវ
ស្រែឆ្ងាយពីផ្ទះ　ឃ្លាតណាស់ពីផ្លូវ　ទំរាំតែទៅ
រលួយស្រូវអស់ ។

កូនអើយកុំឆោត　បើចង់បានត្នោត　ដាំដោយឡៀនកោះ
ដីទួលចំការ　ឯណាចន្លោះ　ដាំដារពោះ
ផាយផ្លូវរបង ។

របៀបចំការ　ថែទាំរក្សា　យូរៗស្រាស់ម្ដង
ស្រាស់ឱ្យត្រូវផ្លូវ　មើលគួរសមផង　កុំបើកមុខឆ្លង
ទៅស្រាស់ខាងក្រៅ ។



មិនគាប់ប្រសើរ　របងវាធ្លើរ　អ្នកម្ខាងវាក្ដៅ
កើតក្ដីកើតក្ដាំ　អស់ទោរអស់ទារ　ទិតអស់ញាតិផៅ
ពីព្រោះចំការ ។

មួយទៀតរបង　ផិតផ្លូវអ្នកផង　គេទៅណា ?
ធ្វើឱ្យខ្ញុំហោឃ　កុំរាយបន្លា　កាប់ឆ្ដើសខាត់ផ្លារ
ឱ្យឆ្ងាយពីផ្លូវ ។

កុំធ្វើចង្អៀត　ក្រែងយប់អ្នកប្រាក្រ　ខ្លះមកខ្លះទៅ
ទៀសខ្លាមិនរួត　បើកបរកាត់ស្រូវ　ដេរម្ខាងតាមផ្លូវ
រហូតដល់ផ្ទះ ។

កូនអើយអ្នកតាំ　អ្នកកុំចចកម្ម　មានការច្រើនណាស់
ជាតិក្រោយខ្វាក់ទិន　កខ្វះកខ្វាស　ល្អវាចាយពីខ្វះ
មិនខាតបុណ្ណាន ។

កុំខ្វាចតែក្រ　ធ្វើបុកមិនល្អ　ច្រើនកើតវិន្នាន
រឿងរអោក　ផាត់ញាតិសន្តាន　ឥតគេរាប់អាន
មានតែគេស្អប់ ។

កាន់បុកឱ្យខ្ពស់　ឱ្យឡើមពាក្យពេញ្ញា　ទើបបានជាគាប់
បើកតោតជាក់ខ្លួន　ច្រើនមានគេរាប់　បើខ្លួនឥតគ្រួញ
កុំឆ្លាប់ហោចខ្លី ។

គ្រប់ការសារពើ ចង្អេរកញ្ជើ កន្លាំងគោញី
រនាស់រនេះ គោសេះក្របី បើបានជាខ្ចី
ខ្ចីប្រាក់គេឲ្យ ។

យកមករកស៊ី ខែមួយខែពីរ សងប្រាក់គេវិញ
របស់បានឡើង ជាដើមជួញចេញ ឯទ្រព្យនោះមិញ
ពេញជាទ្រព្យឯង ។

កុំខ្ចីគេប្រើ តែមួយដំណើរ មិនយូរអង្វែង
កូនជាពាក់បែក ជជែកទាស់ទែង សងគេមិនលែង
ចាស់ផ្លាស់ជាក្ដី ។

កើតមកជាប្រុស គិតឱ្យល្អសុស កុំឱ្យសល់អ្វី
បួសរៀនធម៌អាថ៌ សាស្ត្រាបាលី បរលោកលោកិយ
កុំបីចន្លោះ ។

លើកមករកស៊ី កកាយធរណី ធ្វើជាគ្រហស្ថ
កុហកជឿបុណ្យ បំណុលរុំរោះ ច្រើនគេដាក់ខ្នោះ
អស់ស្រែចំការ ។

ធ្វើរាស្ត្ររកស៊ី ចិញ្ចឹមគោញី ថែទាំព្យាបាល
ព្រោះហេតុពីខ្ជិល មានញៀត ឧស្សាហ៍ អ្នកមានក្រាថ្លា
មិនស្មើគំនិត ។



កំណើតសំណាង សំណៀមពរអាង កកើតពីគិត
ពីកាលជាតិមុន បុណ្យព្រេងអតីត កើតរូបគំនិត
ទើបកើតសំណាង ។

ឯមនុស្សសំណាល់ ល្ងង់ល្ងើជឿងងល់ ទាស់ទែងក្មេងក្លាង
ផប់ឆ្នាំនេះហើយ ប្រកាន់មន្តអាង១ ខ្លះអួតសំណាង
ខ្លះអាងគំនិត ។

កូនចៅប្រុសស្រី រកប្រពន្ធប្ដី ឱ្យរកស្រុកជិត
បើរកស្រុកឆ្ងាយ ឱ្យម្ដាយពិនិត្យ ឱ្យត្រឹមត្រូវពិត
ពូជពង្សាវតា ។

កូនអើយអ្នកចាំ កុំជឿខែឆ្នាំ កុំជឿតម្រា
ពាក្យក្បួនតម្រាយ កើតពីមនុស្សចោរ ពីដូនពីតា
ចោរតាមសម្គាល់ ។

អ្នកជឿតែពូជ អម្បូរធ្លាប់ខូច វាខូចរៀងរាល់
ពូជមានវាមាន ពូជទាល់វាទាល់ កុសលអកុសល
យើងមើលមិនជាក់ ។

ប្រពន្ធនិងប្ដី អាយុវែងខ្លី យើងមើលឃើញច្បាស់
កុំយកពូជល្បែង ពូជក្មេងអារក្ខ បើម៉ូបង់ប្រាក់
រកអាយុវែង ។

អម្បូរពួកពង្ស    ត្រកូលធ្លាប់ខូច    វាខូចមិនលែង
ពួកចោរស្រីៗ    យកប្ដីចិត្តឯង    មិនគិតកោតក្រែង
ខ្លាចចិត្តមេបា ។

កូនចៅស្រីៗ    បើមិនយកប្ដី    ឱ្យមើលក៏វិបរា
មួយភ្លេចមារក្ស    មួយអ្នកចាណា    មួយអ្នកផឹកស្រា
មួយអ្នកចង់ស្រី ។

ពួកអ្នកក្រម៉ាច់    លេងផោមលេងមាចម៍    អាយុច្រើនខ្វី
ប្រកាច់ជាតិលក្ខណ៍    ជាតិមារក្សព្រៃ    មួយតឹមផ្ញើ
ធ្វើក្រមជំទប់ ។

ជំទយតែជើរ    មេស្រុកគេប្រើ    ទាំងថ្ងៃទាំងយប់
មានមួកខ្វះរ៉ព្រ    កម្រមានគ្រប់    មួយទៀតក៏ភប់
ផ្ទុញត្រាំប្រការ ។

ត្រកូលជាខុស    បេក់សព្វទាំងរស់    មិនចេះអធិដ្ឋារ
សព្វសព្វអ្វីៗ    បក្សីបក្សា    ព្រាត់មេព្រាត់បា
ទេវតាលោកលក់ ។

លោកិយនេះខ្សត់    យម្ពូតលតេកត់    ទៅស្ថាននរក
មួយបរូយអាគាំង    ពៅបៀគ្រប់មុខ    កូនអើយចាំទុក
ព្រគ្រប់ត្រាំបី ។



ឯអ្នកទាំងអស់    រកស៊ីម៉េះម៉ស់    ច្រើនជាងស្រីៗ
ព្រឡានោះវែង    ក៏មិនកោះខ្វី    ប្រពន្ធដេរស្ដី
អាងឈ្មោះបំពាន ។

នេះពួកអ្នកក្រ    រស់ទាំងគ្រួសារ    ទាំងអស់ទាំងឃ្លាន
ធ្វើគុណមិនកេ    រកកេសឋ្នាន    ហេតុនេះកុំរៀន
ទាំងត្រាំបីផ្លូវ ។

ហៅអ្នកនេនការ    មិនដែលស្អាត    ធ្វើស្រាបនស្រូវ
ប្រព្រឹត្តិសាងកម្ម    ប្រចាំផ្លូវ    វង្វេងខុសផ្លូវ
ញាណាមសម្លាប់ ។

អន្ទាក់ផុងកុក    អន្រ្គុតឈ្នាងផ្គក់    គ្រប់គ្រឿងប្រដាប់
ផ្ទុកបៀត្រពាំង    ចប់ជំនិតពពាប់    ទោលស្រូវកណ្ដាប់
កណ្ដៀវកាត់អស់ ។

ក៏ពប់ខ្លាត់ឆ្ងាយ    ខូចខាតអន្ដរាយ    មិនឆ្ងាយស្រណោះ
យប់វេរប់ប្រហក់    ចង់បានត្រីរស់    ខែភ្លឺរស់រុះ
ដើរផ្សាញសំណោច ។

វក់តែសប្បាយ    ដើរផ្សាចញ្ឆាយ    ដើរចងសន្ទូច
អំពើអស់នោះ    ច្រើនខ្វះស្រូវពូជ    ធ្វើបាបតិចតួច
អាងជឿគេស៊ី ។

កូនអើយបំណុល ចងការជឿបុល មួយឡើងជាពីរ
អ្នកភ្លេងអារក្ស ច្រើនទិមគោញី មួយឡើងជាពីរ
ធ្វើសោះតែទាន ។

ថ្ងៃដេករកភ្ញាក់ យប់លៀងអារក្ស ឈឺផ្ដាលសន្ធាន
គេស្ដីគេពឹង មិនឈប់ពុំបាន គេរករាប់អាន
កាលមានធុរៈ ។

ផ្លុំប៉ីគូតទ្រ ស្រែកច្រៀងវាយស្គរ មិនបានលុយកាក់
ឯងពឹងគេវិញ គេគ្មានជំពាក់ ពឹងបានម្នាក់ៗ
ដោយសាររឿងថ្លៃ ។

ឡើងត្នោតភ្ជួរស្រែ កម្រទាន់គេ ជ្រិតដេកដល់ថ្ងៃ
ក្រោកកាត់ចង់ឆាប់ ផ្លូវគេពេញថ្ងៃ ចំណោះចង្ក្រៃ
នាំខាតធ្វើការ ។

ឯខ្មោចអារក្ស ស្លាប់ផុតរស់ម្នាក់ ថ្វាយចេកថ្វាយស្រា
សំពះដឹងគុណ ខ្មោចប្រាកដជា មិនដែលអ្នកណា
ដឹងគុណអ្នកភ្លេង ។

ឯអ្នកប្រមឹក ប្រមូលគេផឹក ធ្វើភឿនធឹងក្មេង
សមជីច្រើនពឹង ស្រវឹងវង្វេង ជំពរអ្នកភ្លេង
មិនចេះក្រឡូត ។



អ្នកទាំងបំពាន ផឹកម៉្លៃលុយមាន ផឹកម៉្លៃលុយអត់
ឯងចេះតែកិន មិនចេះតែកត់ ផឹកដល់កំណត់
យកស្រែបញ្ចាំ ។

សល់ផ្ទាលមួយពីរ វាយគោស្ទោរស៊ី មិនគិតខ្លាចកម្ម
ផឹកស្រួលហួសល្បត់ អត់បាយរាល់ឆ្នាំ អស់ស្រែបញ្ចាំ
បញ្ចាំកូនទៀត ។

កំណើតផឹកស្រា ផឹកផុតមេត្តា ផឹកស្រួលហួសមាន
អ្នកមួយផឹកស្មើរ ល្បីល្បើចេះទៀត ម្យ៉ាងផឹកផុតមារយាទ
ច្រើនទៅខ្ញុំចិន ។

រែកទឹកពុះឧស ភាចុញភាពុះ ចាក់តែរផឹកលិច
ស៊ីរែកទំអត់ សំពត់ទើចក្បិន ទំរាំបាយផ្ទិន
មិនផុសហៅស៊ី ។

ឆ្ងាញ់តែម្នាក់ឯង ផ្អែតហើយទំស្ញេង ទំលើកទំលើ
ផងទឹកស្រោចគ្រប់ ស្រោចទ្រឹមម្ទេសជីរ ខ្ញុំមិនម៉្លៃពីរ
វិលទៅរោងផ្ទះ ។

ឯអ្នកចង់ស្រី ប្រពន្ធពីរបី ថាឯងអ្នកណា
គង់ឯសំពត់ តែមួយបន្ទាស់ ពាក់មារបំណាស់
កម្រមានថ្មី ។

ថ្ពះលេចវាយញើង ផញ្ញាំងចងហ៊ឹង ស្វាច័រតាយសី
ខ្ចប្រឹងក្រមួន ម្ទូស្វាតាវី កំឡោះពីរបី
ចោមរោមរៀនស្នេហ៍ ។

រៀនស្គាល់រៀនស្និទ្ធ កើតក្តីពិត្តិត ព្រួយចិត្តឪម៉ែ
កូនអើយប្រពន្ធ អាងមន្តព្វកែ ត្រូវតុកជប់ខែ
អស់ស្រែត្រពាំង ។

ធម្មតាប្រពន្ធ ពានដោយសិល្ប៍មន្ត ដោយស្វាត់កំពាំង
រកស៊ីលៀនខ្វែក ពានរែកខ្ទះឆ្នាំង ពានញើកខ្លាំង
ទៅខ្ទះចង្កៀរ ។

ពានទេះខ្ទះទោះ ព្រហេតុពីព្រោះ អាពុកម្តាយដេរ
បើចូលជំនុំ មិនរម្យចូលគេ អង្គុយរេះរេរ
មិនហ៊ានបារាលមុខ ។

នេះពុតអ្នកប្រ ចាំផាត់ណា ពជាទុំទុក
ប្រយ័ត្នជំទៀល គេទៀលអាពុក កូនអើយចាំទុក
ចាំតកូនចៅ ។

រក្សាពូជពង្ស ធ្វើខ្លួនល្បើកល្បង់ ស្លាប់ចាស់ប្រដៅ
កុំស្អប់អ្នកព្រាល កុំខ្លាចអ្នកខ្មៅ បើមកុលស្រូវផោតផៅ
កូនឯងកុំភប់ ។



កុំភ័យខ្លាចអត់ មើលឲ្យក្រោកជ គួរយកគួរឈប់
គួរលោតគួរលោង គោងមើលឲ្យគ្រប់ កុំចេះតែឈប់
មិនស្គាល់ឪម៉ែ ។

រកប្តីប្រពន្ធ ឲ្យគិតឲ្យគន់ ឲ្យមើលតួនតែ
ត្រកូលអ្នកត្រង់ ក្រោកជតាមខ្សែ បីដូចឈើផ្លែ
មិនតែលេចេះក្លាយ ។

ពុរធ្នូមធ័កូត ដើមក្រូចផ្លែក្រូច ដើមស្វាយផ្លែស្វាយ
ពូជស្រីចោរក្បត់ មិនអត់សាហាវ ពូជស្រីមេម៉ាយ
ពីម្តាយដល់កូន ។

បើលពូជមិនខុស ពូជសាំងចិនប្រុស ទាំងអស់បងប្អូន
ពូជសែនមេតា ពីតាដល់ចុន ពូជល្អសុខស្ងៀម
ពីចុនដល់ចៅ ។

រកប្រមិនប្រ អាក្រក់ហើយសរ មារយាទល្អហើយខ្មៅ
ស្រីក្មេងមានខ្នាស ចាស់ចង់ប្រដៅ ប្រដូចតាមចៅ
មិនស្រូវខុសខាន ។

ពាក្យចាស់បោកថា ធ្វើស្រែចំការ ស្លាប់មហាសក្ត្រាជ
ធ្វើម្តងខុសខាត ធ្វើម្តងទៀតពាន ធ្វើតាមប្រមាណ
ប្រមើលទឹកភ្លៀង ។

រកប្ដីប្រពន្ធ ឱ្យគយឱ្យគន់ រើសរកប្រមាង
ពូជថ្លៃល្មមយក ពូជថោកល្មមវាង ប្រយ័ត្នបុកល្បៀង
នាងកុំប្រសព្វ ។

ជាតិស្រីនិងប្រុស បើបានជាខុស ខុសទាល់ចាស់ចាប់
បើបានប្រល្អ កម្រមានភ័ព្វ មានខុសមិនគាប់
ផ្លូវស្រែចំការ ។

មួយទៀតអ្នកចាំ អាពុកចំណាំ ទុកជាគម្រា
កុំយកគម្រាប់ កុំស្ដាប់អាចារ្យ បើនឹងរៀបការ
កុំការប្រញួន ។

ប្រវែងវេលា ពួស្ដរញើយគ្នា ប្រទប់ប្រទូន
ស្រុកជិតភូមិផង របងដោយខ្លួន អាចារ្យអាងក្បួន
ចាស់ខុសលប្យាយ ។

កូនអើយអ្នកចាំ យូរណាស់៤ឆ្នាំ ព្រាត់ប្រាសអន្តរាយ
ច្រើនស្លាប់ពាធាក់ រស់ម្នាក់មេម៉ាយ កូនឃើញតែម្ដាយ
មិនឃើញអាពុក ។

មានកាលស្លាប់ស្រី ស្លាប់ចោលកូនខ្ចី ប្ដីទៅរកទុក
យកប្រពន្ធទៀត កម្រពេញមុខ កូននិងអាពុក
បែកគ្នាខ្វាត់ខ្វាយ ។



កូនចៅស្រី ៗ បើនឹងយកប្ដី កុំយកពោះម៉ាយ
ស្ងួតនាំម្នាក់ឯង បង្ហែងនឹងម្ដាយ អាណិតរូបកាយ
ស្ដាយខ្លួនក្រមុំ ។

ហៅប្រុសអភ័ព្វ ប្រពន្ធដើមស្លាប់ មានកូនតូចធំ
យកឯងជាចុង បំរុងជាយំ ច្រើនឈ្លោះជុំជុំ
ព្រួយចិត្តម៉ែឪ ។

ហៅប្រុសចិត្តពីរ ពិបាករកស៊ី រញ៉ាំរញ៉ូវ
ឯងទៀបស្មើរស្លាប់ ផ្អាប់ចិត្តមិនត្រូវ បីប្អូនផ្លូវ
ខ្លួនឯងស្លាប់ទៀត ។

ចង្រៃខាងប្រុស កូនអើយចាំចុះ កុំយកខ្លួនបៀត
ស្រីណានាំយក ស្រីនោះបង់មារយាទ ប្រុសព្រួយខ្ទប់ធាតុ
ខ្ទប់គ្រប់ជាបី ។

យកទៀនជាប្អូន គ្រោះផល់ស្លាប់ខ្លួន មេម៉ាយខាងស្រី
ត្រាកដមិនខុស ប្រុសក្នុងលោកិយ ស្មៀនៅអត់ប្ដី
ស្លាប់រស់រូបមួយ ។

បើខ្លួនកំព្រា រីពឹងមីងមា រកស៊ីមិនព្រួយ
កាច់មារយាទល្អ មិនក្រគេជួយ បងប្អូនកូនក្មួយ
រត់ចូលឱ្យប្រើ ។

ពោះម៉ាយមានបី កុំយកធ្វើប្តី មិនគាប់ប្រសើរ
អាមួយស្រីលែង ស្រីគេគ្រាន់បើ ពោះម៉ាយក្លាយជើរ
អាងលែងប្រពន្ធ ។

ពោះម៉ាយទាំងអស់ កុំយកឲ្យសោះ ហៅប្រុសទុរជន
ទុរជាតិអប្រិយ ស្រីកើតទុក្ខធ្ងន់ ហៅមួយជំទាន់
ចំណាំមិនខុស ។

កំឡោះចាស់យូរ ចាស់ទុំគេប្តូរ ល្មមព្រមយកចុះ
រកស៊ីមានបាន សុខសាន្តឥតឈ្លោះ ចំរើនរបស់
អាយុយឺនយូរ ។

កុំយកប្តីប្អូន ជោគរាសីខ្លួន រកស៊ីមិនធូរ
គេហៅឯងធំ សមហៅគេពូ ច្រើនខ្ជិលទុម្ង
ម៉េះមស់ចិងល្បែង ។

វាច្រើនមើលងាយ ហៅស្តីនិយាយ ហៅបងហៅឯង
ខ្លួនយើងជាស្រី ស្រដីឥតក្រែង យល់គេប្អូនឯង
ឯងមើលងាយផេរ ។

ពាក្យចាស់លោកចង ប្តីទុកស្មើបង ប្រពន្ធស្មើម៉ែ
មើលងាយរាល់ថ្ងៃ ចៃប្រារព្វទែ រកស៊ីធ្វើស្រែ
ច្រើនខាតគ្រាប់ស្រូវ ។



គួរយកប្តីបង ពាក្យចាស់លោកចង ទុកប្តីស្មើទី
ខ្លួនឯងប្រមាថ ប្រតិបត្តិឲ្យត្រូវ រាសីគង់នៅ
ទេពរក្សរក្សា ។

ប្រពន្ធមិនប្តី ធំស្រាលលើស្រី គង់គង់កិរិយា
ឈ្មោះហើយគ្រឿងរង្គ ស្រីអង់ពក្ខណា ប្តីខ្ជិលខ្សាហ៍
ព្រោះឫកប្រពន្ធ ។

ជាតិស្រីមានលក្ខណ៍ ទេវតាពុំខាក់ កប់កើតទ្រព្យធន
ប្រទេចជេរវាយ ចៃត្រូទុរជន ជូជាតិលើសលប់
លើសលុបលើប្រុស ។

ហៅកាឡកិណី វាយកូនជេរស្តី មិនដឹងត្រូវខុស
បើមានភ្ញៀវមក ពិតរករឿងឈ្លោះ អសោចសាយសុស
រល្លោះធនធាន ។

រកស្រីមារយាទខ្ពស់ ចេះខ្មើមពាក្យឈ្មោះ ចេះទ្រាំអត់ឃ្លាន
ចេះស្ងួតចេះការ ចេះខ្លាចចេះហ៊ាន ចេះខ្មាសចេះអៀន
កាចមានត្រូផ្លា ។

កូនចៅស្រីប្រុស ចំណាំទុកចុះ ទុកជាតម្រា
គួរយកតម្រាប់ គួរស្តាប់ពុទ្ធដីកា ព្រះអង្គទេសនា
គាថាបួនបទ ។

រៀនក្រាប់អ្នកប្រាជ្ញ    បើចង់ឈ្នះកាច    យកស្លូតសម្លុត
ចង់ឈ្នះមនុស្សខឹង    ឱ្យប្រើងរំអត់    វាជេរវាហត់
វាស្ងប់លែងខឹង ។

ចង់ឈ្នះអសុរោះ    ស្តីលេងឡេះឡោះ    កុំធ្វើជាដឹង
យើងស្តីត្រង់ណា    ឱ្យចំត្រង់ហ្នឹង    ឃើញឫកយើងវឹង
ខ្លាចយើងខាងក្រោយ ។

ចង់ឈ្នះកំណាញ់    ក្រដេក្រដាញ់    សុំអ្វីមិនឱ្យ
បើពានចំណី    ហុចវាញយៗ    តិចដោយច្រើនដោយ
ក្នុងតែវាខឹង ។

នេះមន្តព្រះពុទ្ធ    ត្រផ្ចាឱ្យមុត    ឱ្យគិតថ្លែងថ្លឹង
កុំកាចខុសខ្នាត    កើតខាតផ្សិតវឹង    កុំពើយចំប្រើង
កាច់ច្បាប់ទាំងបួន ។

កុំជួញរវល់    កុំតបតទល់    កើតទាស់គុំគួន
កូនណាកាច់ពួន    កូននោះសុខខ្លួន    ទោសទាស់លែងជួន
លែងជួបមួយជាតិ ។

បើមនុស្សរកគុណ    មកនៅចំណុល    ញេះញុសធ្វើញាតិ
ឱ្យមើលលែលក    កុំយកខ្លួនបៀត    វាគុណទៅទៀត
អសារឥតការ ។



ចំណីចំណុក    ឱ្យស៊ីឱ្យចុក    ឱ្យដោយក្តីមេត្តា
កុំឱ្យជឿខ្ចី    ក្រែងខុសសន្យា    កើតទាស់កាលណា
បើរែករត់បាត់ ។

មនុស្សគ្មានកន្លែង    ខុសពីមារយាទឯង    មិនប្រុងប្រយ័ត្ន
តាមទាន់ពឹងទារ    វាខឹងក្តៅក្តាត់    គុំគួនដោយស្ងាត់
បំភ្លាត់ឯងបាន ។

ហេតុនេះគួរគិត    គួរកូនពិនិត្យ    ច្បាស់សុំរាប់អាន
គួរឱ្យសុំឱ្យ    គួរខានឱ្យខាន    ផ្សិតពាក្យបុរាណ
មានពីរចំណែក ។

ចងទុកជាក្បួន    ចិត្តល្អក្រខ្លួន    នេះពាក្យមួយបែក
មួយទៀតចិត្តល្អ    មិនក្រយូរពេក    ឆ្នាំនេះឆ្នាំស្អែក
ក្នុងតែពីងមាន ។

ចិត្តល្អក្រខ្លួន    ចាំទុកជាក្បួន    ជាក្បាលពិចារ
ឃើញអ្នកទុរគត    កំសត់អត់ឃ្លាន    មិនស្គាល់ពោះវៀន
ហៅនជឿឱ្យខ្ចី ។

ទៅទារមិនឱ្យ    ពិងជឿនញយ ៗ    ខឹងប្តឹងកើតក្តី
ខាតទាំងទ្រព្យចាស់    អស់ទាំងទ្រព្យថ្មី    ស្លូមគោក្របី
រវល់ក្តីខានថៃ ។

ចិត្តល្អមួយទៀត　មេត្រីជាញាតិ　សំដីខ្ទីស្រែ
ពានស្រូវស៊ីស្លប់　ក្រឡប់កាច់កែ　វិលងឆ្នាំវែង
ដកហូតមិនបាន ។

ឯងប្តឹងវាត　ក្តីចាល់តែក្រ　អស់ឆ្នាំងអស់ចាន
របស់ក៏ខាត　របរក៏ខាន　ផងអស់ហ៊ុនធ្នាន
ចំរាំចាញ់ឈ្នះ ។

ប្រពន្ធនឹង ២　ចងការជៀវី　មើលមុខឱ្យច្បាស់
កុំចោលច្បាប់ខ្មែរ　កុំភ្លេចច្បាប់ព្រះ　តាមតែប្រទះ
ប្រទាញសងខាង ។

ចាំចិត្តកណ្តាល　បើនឹងឈើថ្កាល　សប្បុរសមើលយ៉ាង
រៀនស្លូតរៀនព្រហ្ម　កាចកុំឡូងក្លាង　ក្រែងគ្រោះសំណាង
ខ្លោចខាងវាស្លាប់ ។

ល្បួមិនក្រលួរ　ស្វែងរៀនរកគ្រូ　សុំកុំស្លាយទ្រព្យ
ត្រូវវាយកុំខឹង　ឱ្យព្រឹងទំផ្ទាប់　ចេះមន្តសាយសព្វ
ក្រឡប់ជាមាន ។

ធម្មតាអ្នកចេះ　អ្នកស្វែងចំណេះ　ចេះជឿតនំរៀន
ឆ្លាត់គួរស្បរស្បាច់　សាច់សិល្បរមៀន　អ្នកខ្សត់អត់ឃ្លាន
ព្រោះចិត្តអាក្រក់ ។



ខូចចិត្តបញ្ចូលខ្លៅ　ត្រូវគេព្រឺតៅ　រីងណេះសំឡក់
របញ្ជរបុញ　ភូតភរកុហក　ស៊ីបបំពួចកក់
មិនចាំធ្វើស្រែ ។

អ្នកបួចអ្នកលួច　រក់បានតិចតួច　បានគ្រាន់បើដែរ
ជប់គេឃើញមុខ　ត្រូវចុកត្រើនចែវ　អាក្រក់ជប់ម៉ែ
ខូចកេរ្តិ៍ជប់ឪ ។

ចង់ខ្ពស់បានទាប　ចង់មានបង់ភោគ　វែងបាត់ធនទៅ
ពាក្យពីបុរាណ　លោកមានដំរូវ　ប្អូនមនុស្សគ្រប់ឡូវ
ត្រូវតាមពន្យោយ ។

អ្នកលួចអ្នកប្លន់　ចង់បានប្រពន្ធ　ចេញជួញស្រុកឆ្ងាយ
ទិញងាររមេស្រុក　សូកធ្វើចៅហ្វាយ　ចង់ធ្វើងសប្បាយ
ចាយព្រាត់រាជការ ។

ឆព៉ាងបំបាត់　លួចបានដោយស្ងាត់　អាចមានប្រាថ្នា
ក្រឡេចថ្ងាំងដៃ　កាឡែជេះត្រា　ទាស់ភ្នែកទេវតា
រក្សាដែនដី ។

មួយទៀតទូរជន　ធ្វើបាបបានបុណ្យ　គឺបុណ្យមន្ត្រី
ទោសទោចង់ចាប់　កាប់ឥតប្រណី　បានបុណ្យមន្ត្រី
ព្រោះបុណ្យធ្វើបាប ។

អំពើទាំងអស់ កុំសាងឱ្យសោះ ចៀសវាងផលបាប
កាន់សីលព្រះពុទ្ធ និងលុតនិងក្រាប បើក្រពុនផាប
មានទេវតាជួយ ។

កូនអើយទេវតា ស្ថិតសព្វព្រឹក្សា រងោករងួយ
មនុស្សប្រុសឬស្រា ឯណាទីមួយ ទេវតាពុំជួយ
ចំណាំស្គាល់មុខ ។

មិនដែលក៏ពាំង រាជការបារាំង គេចាប់ដាក់គុក
ផុតខ្លួនស្លាប់ទៅ ស្មៀងសោយទុក្ខ សោយទោសនរក
ទាំងពីរកន្លែង ។

នរកបារាំង មានខ្សោយមានខ្លាំង មានខ្លីមានវែង
នរកយមពាល គេផ្ដាលផតក្រែង ព្រះអង្គសំដែង
ថាលានកោដិឆ្នាំ ។

ហេតុនេះគួរវាង គួរចៀសគួរវាង គួរចងគួរចាំ
គួរកុំធ្វើបាប ផលបាបខ្លាចកម្ម គួរកាន់សីលប្រាំ
បណ្ដាំសាសនា ។

ហៃកូនទៅអើយ ក្រឡាប់អស់ហើយ មិនដូចដូនតា
ភ្លៀងផល់ខែប្រាំង រាំងខែវស្សា ឆ្នាំវករកា
ត្រីស័កនេះឯង ។



រនោចផល្លុច រកាពីមុខ ឯកស័កដាក់ស្នែង
ក្នុងខ្មើតផល្លុច ផង់គ្រប់កន្លែង ទាំងគេទាំងឯង
ធ្វើស្រែបាត់ផល ។

ឆ្នាំរោងឆស័ក វិសាខភ្លៀងធ្លាក់ ពីររោចសំគាល់
យប់ថ្ងៃអាទិត្យ ងងឹតព្យុះខ្យល់ ភ្លៀងផង់ពេញថ្នល់
ពេញវាលធំតូច ។

ពេញអូរពេញស្រះ ដើមឈើទាបខ្ពស់ រលុះរលំ
ឫស្សីស្រុកយើង រលើងទាំងគុម្ព ទើបគ្រាប់វាដុំ
ផ្ដួចផុះជាថ្មី ។

ឆ្នាំចត្វស័ក រាំងរីងរហូត គ្រប់ឆ្នាំទាំងបី
កើតទាំងជម្ងឺ ស្លាប់មនុស្សប្រុសស្រី ខាលនោះអស់ភ័យ
ធ្វើស្រែស្រូវបាត់ ។

ភ្លៀងឆ្នាំម្សាញ់ រលើងក្បាលក្រាញ់ ត្រូវតាមបុរាណ
កង្កុកផង់វាល វាលសព្វស្ពាន អ្នកស្ទឹងបុំធ្នាន
រលួយស្រូវអស់ ។

ដាច់ថ្នល់ខាងជើង រាជការគេប្រើ ទាំងចាស់កំឡោះ
មហែងរងកម្ម បញ្ចាំកើតកោះ គ្មានអ្វីស៊ីសោះ
ដាច់ពោះស្មើណក្ស័យ ។

ខែចេត្រឆ្នាំវក ស្រឡះពពក កើតមានសម័យ
ជាហេតុអស្ចារ្យ សុរិយាល្ងាចថ្ងៃ ឧប្បាតចង្រៃ
ឃើញសព្វអីហោះ ។

ពីជើងទៅត្បូង ចាស់ក្មេងមើលព្រួង គេឃើញទាំងអស់
មើលមិនស្គាល់ជាក់ ធ្លាក់ចំចន្លោះ ពាត់ភ្លើងសុទ្ធសោះ
មិនដឹងទៅឯណា ។

កាលមុននោះមក ខែបុស្សឆ្នាំវក លែងមានព្រាហ្ម
មានតែមេស្រុក វាស់បែងក្រឡា ដីមួយហិកតា
ត្រូវតែសើបចាំង ។

រង្វាន់មេស្រុក ត្រូវបង្កមួយទុក ជប់ជូនបារាំង
ទៅដល់ឃុំយ៉រ បណ្ដូរជាក់ឃ្លាំង ពូជពីរគន្លាំង
ក៏ជាប់ពន្ធដែរ ។

ឆ្នាំចុះឆ្នាំតឹង កូនអើយទំព្រើង ជាតិឯងជាខ្មែរ
ក្មេងប្រុសជំទង់ ទៅក្នុងនីម៉ែ រាជការប្រើប្រែ
ថាឱ្យបង់ប្រាក់ ។

កូនចៅប្រុសស្រី កើតមកលើដី ទំរកលុយកាក់
បានហើយទំព្រើង ជុំគ្នាតុជាក់ គ្រាន់ទិញស្លៀកពាក់
បង់ថ្លៃរាជការ ។



កម្របឆ្នាំង ចាប់ពោធិ៍ខ្មៅស ចុតដែកពោះក្រា
ជប់ក្បុរផ្គួតអ្សូវ ដំរុវយ៉ាងណា និងកើតអស្ចារ្យ
របូតរាល់ឆ្នាំ ។

ចតរជើងបែក សប្បាយតែភ្នែក ក្នុងចិត្តរងកម្ម
កូនប្រុសបណ្ដាច់ កុំភ្លេចបណ្ដាំ កញ្ញាសស្រស្អាំ
ត្រីមុំខែបេតជោក ។

ដូចស្លាសំពៅ សំបិលស្លុវស្រូវ មានទៅមានមក
មានចុះមានឡើង រាស្ត្រយើងល្អមរក ល្អមរឡើលោក
ត្រូវយកត្រូវខាត ។

កញ្ញាសតិចឆ្នាំ ត្រូវដាស់ត្រូវដាំ ធ្វើដែងឯងពាន
កុំអាងខ្ទិបពេក កុំដេកឈប់ខាន កុំចោលបុរាណ
ម៉ែនឹងដូនតា ។

ដីពេតរពោក កុំអាងខ្វិលជោក ទៅលេងកែងផ្សារ
កូនចៅស្រី ៗ ខំរៀនធ្វើការ បើគ្មានព្រាហ្ម
មានមាត់ខេះស្តី ។

ឱ្យសួរចាស់ ៗ រៀនពេះកញ្ញាស ផ្ដេចមូរសំឡី
រៀនកូតរៀនការ ត្រសារពាត់រវៃ ហូលពោមពាតក្បី
កុំបីឆន្លោះ ។

រៀនសូត្ររៀនត្បាញ    ឱ្យចាស់បណ្តាញ    បណ្តាក់ខាំងអស់
សំពត់បែបងាយ    លាយស្ព្រែអំពោះ    កុំទិញគេសោះ
ឈ្មោះការជាស្រី ។

ទិញសូត្រតែពាក់    អព្ភូតចេសចាក់    ព្រហូតជាបី
ធ្មេញឃើញឈ្មាន់ផ្សំ    ក្រារម្មក្រារពី    ក្រល់ខ្មាររបស្សី
មុខប្តីជាប្រុស ។

កាពីភ្នាត    ការអ្វីក្រ ២    ទំរៀនទៅចុះ
ទាល់មានចាស់ទៅ    ស្តាប់ត្រូវស្តាប់ខុស    ចាស់ស្លាប់រលស់
គ្មានមនុស្សចេះដឹង ។

រកស៊ីឱ្យញឹក    ដេកយប់រលឹក    រិតត្បិតឱ្យតឹង
បើភ្ញាក់កាលណា    កាន់ការកាលនឹង    កុំណើយទំព្រើង
ទាំងប្រុសទាំងស្រី ។

រមៀតស្លឹកគ្រៃ    ជីរម្ទេសខ្ទឹមខ្ទី    មានដីដាំចុះ
ដាំដើមអ្វី ២    ចំណើរគ្រប់ឈ្មោះ    គ្រឿងស៊ីផ្លែតពោះ
ជុះចោលទទេ ។

ជុះទិសខាងជើង    ជុះដាក់ដីឃើញ    កុំជុះដីគេ
កុំជុះដាក់ផ្លូវ    ត្រូវយាត់ក្មេងដេរ    ដីរលស់ទំនេរ
ល្មមរយាត់ជុះទៅ ។



សក់មួយជាដប់    គ្រៀតលិតឱ្យសព្វ    កុំឱ្យសល់ទៅ
បើក្រជ្ជារាក់    ចាក់ចិត្តឱ្យជ្រៅ    ដាំទេកអំពៅ
ផ្សរស្រូវអង្ករ ។

កើតមកជាមនុស្ស    មួយព្រួយចង់រស់    មួយព្រួយចង់ល្អ
ពីរនេះជាធំ    វាខាំឱ្យក្រ    ចាំជាតំណ
តជាទំនុក ។

មនុស្សមានយាចមិនបិទ    កូនចៅខ្ជិល    ព្រោះម្តាយឪពុក
ធ្វើស្រែមិនត្រូវ    គ្មានស្រូវជម្រក    កូនឈឺយចាំទុក
នេះមុខមេក្រ ។

មេ ១ ជាធំ    កំឡោះក្រមុំ    ស្បៀកពាក់ចង់ល្អ
បើបានបែបខ្មៅ    ថាចៅបែបស    ទើបគ្រាន់អន់ក្រ
ក្រផងចង់ធ្លើង ។

ក្រឡាប់ចគរ    វិបរិតកើតហោរ    ជ្រើនឡើងជ្រើនឡើង
តាលវិតក្រមើត    ទើតម៉ឺតទើងម៉ឹង    ក្រដាសយ៉ាងស្លឹង
ចាយរហែកចៅដៃ ។

ព្រាក់ចាស់អស់ទៅ    ព្រោះមនុស្សឥឡូវ    ខ្ជិលគេចវៃ
ជាតិខ្មែរប្រភេទ    ក្រឡែតក្រឡៃ    ក្រឡាស់សាសន៍ដៃ
សព្វសព្ទធាថា ។

ជាតិខ្មែរប្រុស ស្រីក្លែងធ្វើប្រុស ប្រុសក្លែងធ្វើស្រី
យកប្តីប្រពន្ធ មិនស្គាល់មីងមា បុណ្យខានការងារ
កាប់គ្នាឥតក្រែង ។

ល្ងង់ធ្វើឫកថេះ គោចង្រៃដោកសេះ ប្រុសៗតុះស្នែង
ស្រីពាក់អាវខ្លី ប្រុសពាក់អាវវែង សារុងបៀវកែង
ធ្វើឯងអ្នកក្រាជ ។

កាច់ចិត្តសីហលោ សេះទិមធ្វើគោ ចាក់ហើរពាក់ៗ
រកស៊ីមួយថ្ងៃ ចប់ចានមួយពាន់ បរគោជល់មាន់
ចាក់កាប់ចាប់គុក ។

វិញ្ញូណបៀតើ ជ្រើសទៅផាគោរ ប្រកាសបរាមឥត
ចូរកូនប្រយ័ត្ន ប្រយោជន៍ទៅមុខ ចាំជាទំតុក
តំណកូនចៅ ។

អ្នកកុំប្រហែស រាជការធិរទេស កំចាត់ចេញទៅ
រាជការមាណិត ទំប្រិតប្រដៅ កុំលោភល្ងង់ខ្លៅ
ជោកជៅត្រកូល ។

ប្រយ័ត្នក្រែងក្រ ផ្លូវច្បាប់ល្អៗ អ្នកទំប្រមូល
ផ្លូវវៀចអាក្រក់ អ្នកកុំដើរចូល ហៅផ្លូវមិនស្រួល
លង់ផុតគំនិត ។



ដើរផ្លូវកណ្តាល ស្រឡាញ់ស្និទ្ធស្នាល ណើគ្នាពរដោយពិត
មគ្គផលើលខាន ណោរចូលឡិជិត យកធម៌ជាមិត្ត
មិនឥតអំពើ ។

មនុស្សម្នាក់ជ្រើនកោត ជ្រើនគ្មានគេកោត ណើគ្មានគេមើល
ស្លាប់ឥតគេព្រួយ គេជួយទាំងស្នើរ មិនដែលឡើងលើ
ច្រមុះចុះក្រោម ។

កូនចៅស្រីៗ ក្រមុំសាវខ្លី រៀនចោតឡិល្អម
ប្រុសស្នើម៉ែនី ភ្នែកប្រណោម មើលរូបមើលឆោម
កុំព្រមដោយងាយ ។

កុំក្លិចពូក់ខ្លាញ់ បើចិត្តស្រឡាញ់ កុំចេញនិយាយ
បើស្អប់កុំប្អឹង បើខឹងកុំឆ្ងាយ កុំរោះកុំរាយ
កុំងាយធ្វើស្និទ្ធ ។

កុំដើរក្រាប់គេ កុំអាងមួតដេរ ក្រែងប្រុសណើចិត្ត
ទៅឡិតែខឹង កុំរវល់ធ្វើស្និទ្ធ ប្រុសមិនមាណោត
គិតចូលផល្អិត ។

បើម៉ែនីឡ មើលមុខមើលក្រោយ អាក្រក់ខ្មៅភ្លឹង
ប្រកែកដោយស្ងាត់ កុំខ្លាចម្តាយខឹង កើតកូនមកពឹង
ពិបាកចាយណាស់ ។

កុំឃ្លានចំណី　　កុំខ្លាចអត់ប្តី　　កុំភ័យខ្លាចចាស់
មើលមុខឯងផង　　កុំរើសឥតខ្មាស　　ខ្លួនល្អស្រឡះ
　　　　　　　　មិនខ្វះគេស្តី ។

បើកូនជាខ្លួន　　ទាល់ដើមទៅចុង　　ខែពីរខែបី
រវៀសរវើយប្រញាប់　　ព្រាប់គ្នាស្រី ៗ　　កុំលាក់ធ្វើអ្វី
　　　　　　　　ក្នុងតែគេដឹង ។

កុំមាយាបោះព្រួច　　មាយាទនេះតែខ្លួន　　មាត់នេះតែឯង
គេថាគ្រប់ណា　　ដើរគេគ្រប់ជ្រើង　　ដើរហើយទំព្រើង
　　　　　　　　យកខ្លួនសម្លុត ។

វិនាសវិលុត　　មាក្រក់តែកូន　　អ្នកល្អតែមាត់
មានគេឃើញច្បាស់　　អ្នះវិលបោកសម្ងួត　　ទោសនេះដិតភ្លាត់
　　　　　　　　ធ្លាក់ទៅអវិចី ។

ចោរកាចល្ងង់ខ្លៅ　　ព្រាថ្វព្រាមព្រសៅ　　ហៅតារាធិកស្រី
មេបាកាត់គេ　　ស្លាប់ពីរស្លាប់បី　　វិលុតកូនខ្ចី
　　　　　　　　ស្មើវិនាសព្រះ ។

មានភាពមិនក្បៀយ　　ខ្វិនជើងខ្វិនដៃ　　កន្ទេះកន្ទាស
ខ្វាក់ភ្នែកអគ្គការ　　អចិត្តារូបលោស　　មាក្រក់ក្បើខ្មាស
　　　　　　　　ពកូនពៅ ។



មាសោចីសុសសាយ　　សុសសព្វផល់ម្តាយ　　ផល់ពុចពន្សទៅ
ស្លាប់ទៅរងទុក្ខ　　នរកឋានក្រៅ　　គេស្រុសទឹកក្តៅ
　　　　　　　　ស្លាប់ទៅរស់ទៀត ។

ស៊ីខ្នះយោមឯង　　ព្រះអង្គសំដែង　　ថាមុឺនសែនជាតិ
កើតមកជាប្រេត　　ហេតុកម្មមិនឃ្លាត　　អត់ឃ្លានគ្មានញាតិ
　　　　　　　　បែរកកូនឯងស៊ី ។

ព្រះពុទ្ធបែងប្រាស　　ធម៌សែងសណ្តោស　　សោយទុក្ខវេហ៍
ហេតុចិត្តឫស្យា　　មិច្ឆាទិដ្ឋី　　កើតជាព្រេតញី
　　　　　　　　គេគ្រវគេចាក់ ។

អសប្បុរិសនាំ　　ហេតុផលសេសកម្ម　　កើតជាមនុស្សខ្វាក់
មនុស្សខ្វិនត្រែមត្រម　　ជាគមជាគាក់　　ខ្ទើយគ្នួតអបលក្ខណ៍
　　　　　　　　ជាអ្នកឥតប្តី ។

បើម្តាយជួយព្រួត　　ជួយផាត់វិលុត　　វិនាសកូនខ្ចី
នរកប្រេតព្រមគ្នា　　មិនឃើញរស្មី　　ផ្សិតចិត្តពិរុយ
　　　　　　　　ទាំងម្តាយទាំងកូន ។

ហេតុនេះគួរខ្លាច　　ធម្មតាចោរកាច　　មិនដែលស្ងាត់សូន្យ
មាសោចីកើតហ្លោះ　　ទាំងអស់បងប្អូន　　មេបាដូនតា
　　　　　　　　កាត់កាល់ផែងរាប់ ។

គួរប្រុងជីវិតា    កើតមកទាន់សាសនា    ហៅថាបានមានភ័ព្វ
ទាំងប្រុសទាំងស្រី    កុំបីឱ្យធ្លាប់    គួរខំរៀនស្តាប់
បរលោកលោកិយ ។

ឯខុសនិងគាប់    បើនិងរៀបរាប់    រាល់រូបប្រុសស្រី
គាប់ខុសនៅចិត្ត    ខុសគាប់នៅស្តី    គំរប់ជាបី
ខុសត្រូវនៅកាយ ។

កូនប្រុងក្រឹត្យ    ការកេរ្តិ៍ឱ្យជិត    កុំគិតឱ្យឆ្ងាយ
កើតមកជាខ្មែរ    កុំប្រែភ្លេចកាយ    ធម្មតាសប្បាយ
វាតែងឱ្យទុក្ខ ។

ឱ្យទោសទាស់ទែង    ទាស់តែម្នាក់ឯង    ដល់ម្តាយឪពុក
រីឯរៀងទោស    មានតែពីរមុខ    មួយទៅនរក
មួយនាលោកិយ ។

លោភាទោសាមោហា    កើតពីមោហា    រាល់រូបប្រុសស្រី
គួរកាន់មេត្តា    កតញ្ញូខន្តី    នេះគឺបាបី
ទៅកាន់បរលោក ។

ពាក្យពិតប្រដៅ    ឲ្យអស់កូនចៅ    ប្រព្រឹត្តរៀនយក
កូនណាមិនរៀន    កូននឹងមានយានទោក    និងធ្លាក់ជ្រុលជ្រក
ក្នុងចតុរាបាយ ។



ធំស្រួចនៅស្ងួត    សុខខ្លួនរហូត    ជរាបែរឆ្ងាយ
ខន្តីអំណត់    សង្កត់ក្នុងកាយ    ជាតិជនទាំងឡាយ
កម្រកាន់បាន ។

នេះហើយមិនដឹង    ចិត្តនៅម្ចះរឹង    ប្រឹងរកកម្មឋាន
រកធម៌មិនយល់    និងខ្វល់ណែបខាន    បន្ទោសបុរាណ
ថាគ្មានជិតស្រ័យ ។

រំពាបនិងបុណ្យ    មានចិត្តជាមុន    មាត់ជាបច្ច័យ
នាំតុះនាំញៀង    ពីជើងពីដៃ    សព្វសព្ទថ្ងៃ
ឈ្មោះហៅសំណាង ។

កើតក្នុងលោកិយ    រាល់រូបប្រុសស្រី    មានចិត្តជាមាង
កុសលអកុសល    ប្រមាញ់សងខាង    រូបនៅតែងតាង
តែងនៅតែងមក ។

មគ្គផលសីលទាន    បើល្អង់ឱ្យរៀន    បើគ្មានឲ្យរក
យល់ល្អលាងស្អាត    សង្ខាតគ្រៀតក្រក    ជ្រើសរើសរៀនយក
រក្សារូបកាយ ។

នេះគឺហៅច្បាប់    ជាទីសណ្តាប់    សន្តានទាំងឡាយ
កូនចៅប្រុសស្រី    កុំបីនឿយណាយ    សង្ខេបបរិយាយ
និត្តិតែងចប់ ។

អ្នកព្រះភិរម្យ អាចារ្យជុំយខ្ញុំ បង្គំក្រោមជប់
បើសាពសល់ផ្កាម្លូង វិលោងពុំកាប់ ពុំគួរសមសព្វ
សូមសាយសេចក្តី ។

កាយកម្មវចីកម្ម ពេញ្ញាះច្បាប់បណ្តាំ កូនចៅប្រុសស្រី
ផាបមេត្តាជ្រៅ មិនហៅពលី បរលោកលោកិយ
ទាំងពីរកន្លែង ។

បើលោកឯណា នេះចាំចម៉ីអាចិ ព្រោកជាក់ស្តែង
ឃើញខុសត្រង់ណា កុំថាជាល្បែង ព្បិតពាក្យខ្ញុំតែង
ឲ្យក្មេងវាភ័យ ។

មិនមែនភូតភរ កុំថាខ្ញុំអួត ព្រថាខ្ញុំវៃ
ឃើញមនុស្សវង្វេង ខ្ញុំតែងច្បាប់ថ្មី អស់អាចិសេចក្តី
ឯវិចប់លោង ។